

ទេ! សារ៉េត ។ ដំណាំរបស់យើងគឺមានសុវត្ថិភាពល្អ ។ អនុញ្ញាតិអោយខ្ញុំពន្យល់ប្រាប់ឯងពីមូលហេតុនេះ ។"

ភូមិសំឡូតរបស់យើង គឺជាលំនៅឋានសម្រាប់គ្រួសារជាច្រើនដែលជាអ្នកដាំដំណាំសណ្តែកសៀង ។ ប៉ុន្តែភូមិសំឡូតក៏ជាភូមិឋានសម្រាប់សត្វល្អិតជាច្រើនផងដែរ ដូចជាពួកមួយនេះ ( ស្រឹងបៃតង) ពីព្រោះពួកវាចូលចិត្តជញ្ជក់បឺតយករុក្ខរសពីផ្លែសណ្តែកសៀងណាស់ ។

មានកសិករជាច្រើនគ្រួសារបានបាញ់ថ្នាំពុលលើដំណាំរបស់ពួកគេដើម្បីសម្លាប់សត្វល្អិតទាំងនោះ ប៉ុន្តែវិធីសាស្រ្តនេះមិនមានប្រសិទ្ធភាពគ្រប់ពេលនោះទេ ។ ឪពុកម្តាយខ្លះបានគិតថា ការបាញ់ថ្នាំពុលគឺជាវិធីសាស្រ្តមួយដ៏ប្រសើបំផុត ប៉ុន្តែបានតែមួយឆ្នាំប៉ុណ្ណោះ ឆ្នាំក្រោយៗមកទៀតមិនបានលទ្ធផលល្អទេ ។ ពួកគេបានចាប់ផ្តើមឆ្ងល់ថាតើមានវិធីសាស្រ្តផ្សេងណាដែលល្អជាងនេះឬទេ ។

សំណាងល្អ! មានអ្នកជិតខាងម្នាក់មានដំណាំល្អនៅឆ្នាំនោះ ហើយបានផ្តល់ដំបូន្មានដល់ពួកយើង ។ នាងនោះបានប្រាប់យើងនូវរឿងមួយ ដែលយើងមិនអាចបំភ្លេចបានជារៀងរហូត ...។







កសិករឈ្មោះ តារា ប្រពន្ធរបស់គាត់ឈ្មោះ ចិន្តា និងកូនស្រីឈ្មោះ ធីតា គឺជាកសិករដែលដាំដុះដំណាំសណ្តែកសៀង ។ ពីមួយឆ្នាំទៅមួយឆ្នាំ ទិន្នផលដំណាំរបស់ពួកគាត់ចេះតែបានតិចទៅៗជាដរាប ។ នាឆ្នាំនេះ ដំណាំរបស់ពួកគាត់ស្ទើរតែមិនបានផលផង ។



កសិករតារា បានធ្វើអ្វីៗគ្រប់បែបយ៉ាងនៅក្នុងចំការរបស់គាត់ ។ គាត់បានបាញ់ថ្នាំពុលជារឿយៗតាមដែលគាត់អាចកំចាត់ពួកស្រឹង ដែលបានធ្វើអោយដំណាំសណ្តែកសៀងរបស់គាត់មើលទៅមិនល្អ និងក្រៀមស្វិតស្រពោនតូច ។

នាពេលរដូវភ្លៀងធ្លាក់បានមកដល់ កសិករតារា បានធ្លាក់ខ្លួនឈឺជាទម្ងន់ ។ គាត់ក្អកយ៉ាងខ្លាំង និងមិនមានកម្លាំងកំហែងដូចដែលគាត់ធ្លាប់មានកន្លងមកនោះទេ ។ នៅកណ្ដាលអាធ្រាត្រយប់មួយនោះ មានរថយន្តពេទ្យសង្គ្រោះបន្ទាន់មួយបានឈប់ចតនៅខាងក្រៅ ហើយបាននាំយកកសិករតារាទៅកាន់មន្ទីរពេទ្យ ។



នៅពេលធីតាភ្ញាក់ពីដំណេកនាវេលាពេលព្រឹក នាងបានឃើញម្ដាយរបស់នាងឈរនៅក្បែរគ្រែរបស់នាងគេង ។

ចិន្ដា - បាននិយាយប្រាប់ធីតាថា "ធីតា! ឪពុករបស់កូនត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យកាលពីយប់មិញនេះ ដោយសារជម្ងឺរបស់គាត់មានសភាពធ្ងន់ធ្ងរ " ។

ធីតាមិនដឹងថារកពាក្យអ្វីយកមកនិយាយបាន ។ នាងមានការព្រួយបារម្ភយ៉ាងខ្លាំង ។

កន្លងមកជាច្រើនថ្ងៃ ធីតាមានភាពក្ដុកក្ដួលក្នុងចិត្តយ៉ាងអនេកអនន់ ។ នាងមានការនឹករលឹកដល់ឪពុករបស់នាងយ៉ាងខ្លាំង ។ ប៉ុន្ដែនាងនៅតែបន្តខិតខំប្រឹងប្រែងបំពេញការងារផ្ទះដោយភាពឧស្សាហ៍ព្យាយាម ព្រមទាំងសង្ឃឹមថាឪពុករបស់នាងនឹងមានសុខភាពល្អ នៅពេលដែលគាត់ត្រឡប់មកផ្ទះវិញ ។



នៅរសៀលថ្ងៃមួយ ខណៈពេលដែលនាងកំពុងមើលថែទាំប្អូនប្រុសរបស់នាង ភ្លាមៗនោះ ធីតាបាននឹកគិតក្នុងចិត្តថា: *តើយើងនឹងត្រូវធ្វើអ្វីឥឡូវនេះ នៅពេលដែលគ្មានវត្តមានឪពុកនៅទីនេះដើម្បីមើលថែទាំដំណាំ?* ។

នៅថ្ងៃមួយ ម្ដាយរបស់ធីតាបាននិយាយទៅកាន់នាង នៅពេលដែលនាងត្រឡប់មកពីសាលារៀនមកដល់ផ្ទះ "ឥឡូវនេះដល់ពេលដែលត្រូវដាំដំណាំហើយ" ។

ធីតាបានឆ្លើយតបទៅកាន់ម្ដាយរបស់នាងថា "ប៉ុន្ដែពួកស្រឹងនឹងស៊ីបំផ្លាញវា ។ យើងមិនមានការបាញ់ថ្នាំពុលទេ" ។

ម្ដាយរបស់នាងបាននិយាយ "ធីតា! ស្ដាប់ម្ដាយកូន-យើងត្រូវតែដាំ ពីព្រោះយើងគ្មានវិធីផ្សេងទៀតដើម្បីរកប្រាក់ចំណូលក្នុងគ្រួសារទេ" ។







ធីតាបានស្ដាប់បង្គាប់ម្ដាយរបស់នាង ព្រមទាំងបានជួយម្ដាយរបស់នាងជាច្រើនថ្ងៃក្នុងការដាំគ្រាប់ដំណាំដែលពួកគេបានប្រមូលផលបានកាលពីឆ្នាំមុន ។

"ខ្ញុំនឹងមើលថែទាំពួកឯង-អាគ្រាប់តូចៗ"-ធីតាបាននិយាយ ។ "ខ្ញុំនឹងមើលឯងដុះ និងពិនិត្យមើលអ្វីដែលបង្កគ្រោះថ្នាក់ដល់ពួកឯង" ។





ធីតា បានចំណាយពេលជាច្រើនម៉ោងរៀងរាល់ថ្ងៃ ដើម្បីតាមដានមើលសត្វល្អិតវារឡើងលើដើមដំណាំរបស់នាង ។ គ្មានឃើញសត្វល្អិតណាមួយហាក់ដូចជាបានធ្វើអ្វីច្រើនគួរអោយកត់សំគាល់នោះទេ ។





នៅពេលដែលដំណាំដល់ពេលបាញ់ថ្នាំពុលលើកទីមួយ ធីតាបាននឹកគិតដល់ឪពុករបស់នាង។ នាងបាននឹកស្រមៃដល់សកម្មភាពរបស់គាត់នៅក្នុងអារម្មណ៍របស់នាង- "អាវសឺមីស្ដើង មានភាពរលុងៗ និងខោកន្ទ្រីកកន្ទ្រាក ព្រមទាំងស្ពាយធុងបាញ់ថ្នាំយ៉ាងធំមួយពីក្រោយខ្នង"។



គាត់បានកាន់បំពង់បាញ់ថ្នាំវែងមួយនៅដៃខាងឆ្វេងរបស់គាត់ ហើយដៃខាងស្តាំបានសប់ធុងបាញ់ថ្នាំចុះឡើងៗ ដើម្បីបញ្ជូនទឹកថ្នាំពុលចេញមកក្រៅតាមបំពង់បាញ់ថ្នាំ។ គាត់បានធ្វើការងារជាច្រើនម៉ោងនៅក្នុងចំការ ដោយដើរទៅ ដើរមកតាមចន្លោះរងដំណាំ និងគ្រវីបំពង់បាញ់ថ្នាំពីម្ខាងទៅម្ខាង។

ប៉ុន្តែមិនមែននៅឆ្នាំនេះទេ។